ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

L202306200693TD3473

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## កិច្ចប្រជុំពិភាក្សាអំពីការផ្តល់សេវាពន្ធដារ ជូនសហគ្រាសទិញ-លក់រថយន្ត ដើម្បីជំរុញការចុះបញ្ជីពន្ធដារ និងការបំពេញកាតព្វកិច្ចសារពើពន្ធ

ថ្ងៃពុធ ៤ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ៩:០០នាទីព្រឹក ថ្ងៃពុធ ៤ កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២៣ នៅអគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកិច្ចប្រជុំពិភាក្សាអំពីការផ្តល់សេវាពន្ធដារ ការជំរុញការចុះបញ្ជីពន្ធដារ និងការបំពេញកាតព្វកិច្ចសារពើពន្ធ ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** និងឯកឧត្តម **ហេង សុខណាង** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនាយកដ្ឋាន សាខាពន្ធដារខណ្ឌ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធ ព្រមទាំងវិស័យឯកជនមានការចូលរួមពីលោកឧកញ៉ា **ឈុន គីមស្រ៊ុន** ជាប្រធានសមាគម អ្នកលក់យានយន្តកម្ពុជា និងសមាជិក សមាជិកានៃសមាគមអ្នកលក់យានយន្តកម្ពុជា សរុបចំនួន **៥០រូប**។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ហេង សុខណាង** មានមតិស្វាគមន៍ និងថ្លែងសុន្ទរកថាបើកកិច្ចប្រជុំពិភាក្សា ដោយវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់លោកឧកញ៉ា លោក លោកស្រី នាងកញ្ញា ជាថ្នាក់ដឹកនាំ និងសមាជិក សមាជិកានៃ

សមាគមអ្នកលក់យានយន្តកម្ពុជា( Cambodia Auto Dealers Association-CADA ) និងមន្ត្រីរាជការពន្ធដារ ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំដ៏មានសារសំខាន់នេះ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ ក្នុងការឈ្វេងយល់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀតនូវកាតព្វកិច្ចចុះបញ្ជីពន្ធដារ និងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់អ្នកលក់យានយន្តនៅកម្ពុជា។ ជាមួយនេះ ឯកឧត្តមបានលើកទឹកចិត្តដល់សមាជិកនៃសមាគមអ្នកលក់យានយន្តកម្ពុជា ឱ្យចូលរួមជំរុញ និងចងក្រងពង្រីកសមាជិកឱ្យបានកាន់តែច្រើន ដើម្បីចូលរួមចុះបញ្ជីពន្ធដារ និងបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវ សំដៅធានានូវតម្លាភាព និងការប្រកួតប្រជែងដោយស្មើភាពរវាងអ្នកប្រកបអាជីវកម្មលក់យានយន្តទាំងអស់។

គួររំលឹកថា ការរៀបចំកិច្ចប្រជុំនេះ ជាវេទិកាពិភាក្សាក្នុងការចូលរួមដោះស្រាយនូវរាល់បញ្ហាប្រឈមនានា ស្វែងរកមធ្យោបាយដើម្បីជំរុញអ្នកប្រកបអាជីវកម្មលក់យានយន្ត ចូលខ្លួនចុះបញ្ជីពន្ធដារ បំពេញកាតព្វកិច្ចសារពើពន្ធ និងធ្វើការផ្សព្វផ្សាយច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងកាតព្វកិច្ចទាំងនេះ ក៏ដូចជាឆ្លើយតបនូវរាល់ចម្ងល់របស់សមាជិកនៃសមាគមអ្នកលក់យានយន្តកម្ពុជាប្រកបដោយសង្គតិភាពជាមួយព័ត៌មានត្រឹមត្រូវចៀសវាងភាពស្រពេចស្រពិល ដែលកន្លងមកអ្នកប្រកបអាជីវកម្មមួយចំនួនមានការភាន់ច្រឡំចំពោះការបំពេញកាតព្វកិច្ចសារពើពន្ធ។ កិច្ចប្រជុំពិភាក្សានេះក៏មានការធ្វើបទបង្ហាញស្តីពី "**កាតព្វកិច្ចសារពើពន្ធសម្រាប់សហគ្រាសទិញ-លក់រថយន្ត**" ដោយលោក **ម៉ូ ពិសិដ្ឋ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម។

បន្ទាប់ពីការធ្វើបទបង្ហាញលើប្រធានបទខាងលើរួច ឯកឧត្តមបណ្ឌិត **គុន សម្បត្តិ** បានលើកឡើងថា អនុលោមតាមមាត្រា២០៣ នៃច្បាប់ស្តីពីសារពើពន្ធបានចែងថា **១. បុគ្គលទាំងឡាយត្រូវចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងអំឡុង ១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្តើមធ្វើសកម្មភាពសេដ្ឋកិច្ចឬសកម្មភាពផ្សេងទៀត រួមទាំងសកម្មភាពរបស់ស្ថាប័នឬអង្គការនានា... ២. បុគ្គលទាំងឡាយត្រូវជូនដំណឹងទៅរដ្ឋបាលសារពើពន្ធ ក្នុងអំឡុងពេល ១៥ ថ្ងៃ ក្រោយពីការផ្លាស់ប្តូរអាសយដ្ឋាន ទ្រង់ទ្រាយ នាមករណ៍ កម្មវត្ថុអាជីវកម្ម ការផ្ទេរ ការបញ្ឈប់អាជីវកម្ម សមាសភាពអ្នកគ្រប់គ្រង ឬអ្នកទទួលបន្ទុកកិច្ចការពន្ធដាររបស់សហគ្រាស**។ សកម្មភាពសេដ្ឋកិច្ច សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្តឬមួយដងមួយគ្រា ដើម្បីរកឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ ឬមានបំណងផ្គត់ផ្គង់ទំនិញ ឬសេវាដល់បុគ្គលដទៃក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ។ ជាមួយគ្នានេះ មាត្រា២០៥ នៃច្បាប់នេះ បានចែងថា "**រដ្ឋបាលសារពើពន្ធមានសិទ្ធិចុះបញ្ជី ចំពោះបុគ្គលទាំងឡាយដែលច្បាប់បានកំណត់ឱ្យចុះបញ្ជីហើយពុំបានមកចុះបញ្ជី ក្នុងករណីនេះ រដ្ឋបាលសារពើពន្ធអាចកំណត់កាលបរិច្ឆេទមានប្រសិទ្ធភាពនៃការចុះបញ្ជី**"។ ឯកឧត្តមបណ្ឌិតអគ្គនាយករង ក៏បានគូសរំលេចអំពីអត្ថប្រយោជន៍នៃការចុះបញ្ជីពន្ធដារសម្រាប់សហគ្រាស ដែលរួមមាន៖ ១. មានឈ្មោះជាសហគ្រាសបានអនុវត្តត្រឹមត្រូវតាមច្បាប់កំណត់ ២. ចៀសផុតពីការចុះបញ្ជីជាឯកតោភាគី ៣. ទទួលបាននូវសេវាផ្តល់ព័ត៌មានជាប្រចាំអំពីដំណើរការនៃប្រព័ន្ធពន្ធដារ និងនីតិវិធីនៃការកំណត់ពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារ ៤. សម្រាប់យន្តការអាករលើតម្លៃបន្ថែមនៅពេលលក់ឱ្យ អតិថិជនជាបុគ្គលជាប់អាករ បុគ្គលនោះអាចទទួលបានអាករលើធាតុចូល ដើម្បីធ្វើការកាត់កងជាមួយអាករលើធាតុចេញ ៥. ចំពោះចំណាយរបស់បុគ្គលជាប់អាករនោះ អាចអនុញ្ញាតឱ្យកាត់កងបាន ៦. ទទួលបានការលើកទឹកចិត្តផ្សេងៗ ស្របតាមគោលនយោបាយផ្នែកពន្ធដាររបស់រាជរដ្ឋាភិបាល ៧. ការប្រកួតប្រជែងដោយស្មើភាពរវាងអាជីវកម្មនិងអាជីវកម្ម ៨. អាចទទួលបានការទុកចិត្តពីអ្នកវិនិយោគទុនក្នុងនិងក្រៅប្រទេស ក្នុងការសម្រេចធ្វើការវិនិយោគជាមួយសហគ្រាស ដែលមាន អនុលោមភាពសារពើពន្ធ ៩. អាចប្រើប្រាស់វិញ្ញាបនបត្រចុះបញ្ជីពន្ធដារ និងប័ណ្ណពន្ធប៉ាតង់ក្នុងកិច្ចជានាក្នុងគោលដៅផ្សេងដូចជា ការស្នើសុំហិរញ្ញប្បទានពីធនាគារពាណិជ្ជ សម្រាប់ពង្រីកអាជីវកម្ម ឬការស្នើសុំទិដ្ឋាការចូលប្រទេសនានា ១០. អាចចូលរួមដេញថ្លៃក្នុងការផ្គត់ផ្គង់ទំនិញឬសេវា ដោយប្រើប្រាស់ថវិការដ្ឋ ១១. ចូលរួម

ចំណែកក្នុងការបង់ពន្ធចូលថវិការដ្ឋ ដើម្បីចូលរួមអភិវឌ្ឍសេដ្ឋកិច្ច-សង្គមឱ្យបានរីកចម្រើន សំដៅលើកកម្ពស់កិត្យានុភាពឱ្យកាន់តែខ្ពស់ត្រដែតនៅលើឆាកអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និង១២. អត្ថប្រយោជន៍ផ្សេងៗទៀតផងដែរ។

នៅក្នុងកិច្ចប្រជុំនេះ សមាជិកនៃអង្គប្រជុំបានចូលរួមផ្តល់យោបល់ និងលើកឡើងពីការតាំងចិត្តផ្តល់កិច្ចសហការជំរុញសមាជិកនៃសមាគមអ្នកលក់យានយន្តកម្ពុជា ក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ ព្រមទាំងបានលើកជាសំណួរយ៉ាងផុសផុលដើម្បីជាការពិភាក្សាចែករំលែកចំណេះដឹង និងចំណេះធ្វើ ទាំងបទប្បញ្ញត្តិ ទាំងការអនុវត្ត និងមានការលើកឡើងនូវសំណូមពរពាក់ព័ន្ធផងដែរ។ ទន្ទឹមនឹងនេះ លោក **ឌី សុខុន** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម បានស្នើសុំនូវកិច្ចសហការពីសមាគមអ្នកលក់យានយន្តកម្ពុជាផ្តល់នូវបញ្ជីឈ្មោះសមាជិកនៃសមាគមទាំងអស់ ដែលបានចុះបញ្ជីពន្ធដាររួចរាល់ ដើម្បីឱ្យអគ្គនាយកដ្ឋានពន្ធដារផ្តល់នូវសេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ជាកិច្ចបញ្ចប់ ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** បានបញ្ជាក់ថា គិតមកដល់ពេលនេះ មានសហគ្រាសប្រកបអាជីវកម្មលក់យានយន្តចំនួន **៥១៨ សហគ្រាស** ហើយដែលបានចុះបញ្ជីពន្ធដាររួចរាល់ និងកំពុងបំពេញកាតព្វកិច្ចសារពើពន្ធក្នុងព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តមបណ្ឌិតក៏បានអំពាវនាវដល់ថ្នាក់ដឹកនាំ និងសមាជិក សមាជិកាដែលបានចូលរួមក្នុងកិច្ចប្រជុំពិភាក្សានេះ រួមទាំងអ្នកប្រកបអាជីវកម្មលក់រថយន្តទាំងអស់ដែលជាសមាជិក និងមិនមែនជាសមាជិកសមាគមព្យាយាមឈ្វេងយល់ឱ្យកាន់តែច្បាស់ថែមទៀតនូវបទប្បញ្ញត្តិ នីតិវិធីនៃការចុះបញ្ជីពន្ធដារ ការបំពេញកាតព្វកិច្ចសារពើពន្ធ និងលើកទឹកចិត្តអ្នកប្រកបអាជីវកម្មលក់រថយន្តទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ចូលខ្លួនចុះបញ្ជីពន្ធដារ និងបំពេញកាតព្វកិច្ចឱ្យបានត្រឹមត្រូវ ដើម្បីលើកកម្ពស់វប្បធម៌បង់ពន្ធ និងអនុលោមភាពសារពើពន្ធនៅកម្ពុជា។ ជាមួយគ្នានេះ ក្រោយបញ្ចប់កិច្ចពិភាក្សានេះ ប្រសិនបើសមាជិក សមាជិកានៃសមាគមនៅមានចម្ងល់ពាក់ព័ន្ធនឹងបទប្បញ្ញត្តិ នីតិវិធីចុះបញ្ជីពន្ធដារ និងការបំពេញកាតព្វកិច្ចសារពើពន្ធ សមាជិកនៃសមាគមអាចធ្វើការពិភាក្សាបន្ថែមតាមរយៈកម្មវិធី GDT Live Chat ឬទូរស័ព្ទលេខ ០២៣ ៨៨៤ ៤៨៥ ឬតាមរយៈមជ្ឈមណ្ឌលផ្តល់ព័ត៌មានទូរស័ព្ទលេខ ១២៧៧ ឬដោយផ្ទាល់ជាមួយនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ឬដោយផ្ទាល់ជាមួយមន្ត្រីជំនាញទទួលបន្ទុកតាមសាខាពន្ធដារនីមួយៗ។

កិច្ចប្រជុំពិភាក្សានេះ បានប្រព្រឹត្តទៅដោយរលូននិងបានបញ្ចប់នៅវេលាម៉ោង ១២:០០នាទីថ្ងៃត្រង់ នៅថ្ងៃខែឆ្នាំដដែល ដោយទទួលបានលទ្ធផលជាផ្លែផ្កាក្រោមកិច្ចសហការល្អពីសមាជិកទាំងអស់គ្នា៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ